មាន ប.ស.ស. គ្រួសារសុខសាន្ត



បេឡាជាតិសន្តិសុខសង្គម

# ព្រឹត្តិបត្រព័ត៌មានប្រចាំខែ

លេខ៖៧

## មាតិកា

### ព្រឹត្តិការណ៍សំខាន់ៗ

➤ ព្រឹត្តិការណ៍សំខាន់ៗ........................................................២

### ការផ្សព្វផ្សាយ និងបញ្ជ្រាបព័ត៌មាន

➤ ការផ្សព្វផ្សាយ និងបញ្ជ្រាបព័ត៌មាន របស់បេឡាជាតិសន្តិសុខសង្គម ទៅកាន់សាធារណជន ជាពិសេសសមាជិក ប.ស.ស............២២

### ការស្នើសុំតាវកាលិក (Online)

➤ របៀបប្រើប្រាស់ ការស្នើសុំតាវកាលិកពី ប.ស.ស. តាមកម្មវិធីទូរសព្ទដៃ ប.ស.ស. (NSSF Member App) ....................២៤


## រចនាសម្ព័ន្ធព្រឹត្តិបត្រ ខែធ្នូ ឆ្នាំ២០២៥

**ឯកឧត្តម ម៉េង ហុង**
**អគ្គនាយក ប.ស.ស.**

| | |
|---|---|
| **ចាងហ្វាង** | ឯកឧត្តមបណ្ឌិត **ហេង សុផាន់ណារិទ្ធ** |
| **និពន្ធនាយក** | លោក **អ៊ុក សំអូន** |
| **និពន្ធនាយករង** | លោកស្រី **ចាន់ ស៊ីណូន** |
| | លោក **យុន វិចិត្រ** |
| **លេខានិពន្ធ** | លោក **យន គន្ធា** |
| | លោក **យង់ សុខន** |
| **ផ្នែកការីកុំព្យូទ័រ** | លោក **អ៊ុង ស៊ីខឿ** |
| | អ្នកស្រី **ទិត បញ្ញា** |


សូមអានបន្តនៅទំព័រទី២

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# ពិព័រណ៍ការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅខេត្តសៀមរាប បានផ្តល់ឱកាសការងាររាប់ម៉ឺនកន្លែងដល់អតីតពលករមកពីប្រទេសថៃ

## កម្រងរូបភាពសកម្មភាព




នៅថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០២៥ បេឡាជាតិសន្តិសុខសង្គម ប.ស.ស. និង ទីភ្នាក់ងារជាតិមុខរបរ និងការងារ (NEA) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សហការជាមួយសហភាពសហព័ន្ធយុវជនកម្ពុជា និងរដ្ឋបាលខេត្តសៀមរាប រៀបចំ "ពិព័រណ៍ការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ សម្រាប់បងប្អូនអតីតពលករដែលត្រឡប់មកពីប្រទេសថៃ" នៅខេត្តសៀមរាប ។

ក្នុងកម្មវិធីនេះដែរ **ឯកឧត្តម ហេង សួរ** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានអញ្ជើញជាអធិបតីក្នុងពិធីបើកពិព័រណ៍ការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ សម្រាប់បងប្អូនអតីតពលករដែលត្រឡប់មកពីប្រទេសថៃ ដោយនាំយកឱកាសការងារប្រមាណជាង ៨ម៉ឺនកន្លែង និងព័ត៌មានស្តីពីអត្ថប្រយោជន៍នៃរបបសន្តិសុខសង្គម ក៏ដូចជាព័ត៌មានស្តីអំពីការបណ្តុះបណ្តាលជំនាញបច្ចេកទេសវិជ្ជាជីវៈដោយឥតគិតថ្លៃផងដែរ។

ថ្លែងក្នុងឱកាសនោះ **ឯកឧត្តមរដ្ឋមន្ត្រី** បានលើកឡើងថា ការធ្វើការងារនៅក្នុងស្រុកមានភាពល្អប្រសើរជាងការធ្វើការនៅប្រទេសថៃ ដូចជាការទទួលបានអត្ថប្រយោជន៍ ប.ស.ស. ដែលរួមមាន ការព្យាបាលជំងឺដោយឥតគិតថ្លៃពេលឈឺ ឬពេលមានគ្រោះថ្នាក់ ទទួលបានប្រាក់សោធន អាចរស់នៅជួបជុំក្រុមគ្រួសារ អាចចូលរួមពិធីបុណ្យប្រពៃណីជាតិនានា ក៏ដូចជាពិធីជួបជុំនានាផងដែរ ហើយម្យ៉ាងទៀតដោយសារយើងជាខ្មែរដូចគ្នា គឺមានភាពងាយស្រួលក្នុងការទំនាក់ទំនង និងយោគយល់គ្នា ជាពិសេសនៅកន្លែងធ្វើការតែម្តង។

សូមបញ្ជាក់ថា កម្មវិធីពិព័រណ៍ខាងលើប្រព្រឹត្តទៅនៅថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០២៥ ធ្វើនៅក្នុងបរិវេណសាលាបឋមសិក្សា សម្តេច ហ៊ុនសែន រណសិរ្សត្រីភូមិ ឃុំដំដែក ស្រុកសូទ្រនិគម ដោយមានអ្នកចូលរួមប្រមាណជាង ១ពាន់នាក់។

ដូច្នេះសម្រាប់បងប្អូនប្រជាពលរដ្ឋខ្មែរទាំងអស់ ជាពិសេសបងប្អូនពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃដែលកំពុងស្វែងរកការងារធ្វើ ឬចង់ផ្លាស់ប្តូរការងារ គឺអាចធ្វើការប្រឹក្សាយោបល់បានភ្លាមៗ ឬក៏អាចសាកសួរព័ត៌មានបន្ថែមតាមរយៈលេខទូរសព្ទ Hotline ១២៩៧។ ដោយឡែកសម្រាប់ចម្ងល់ផ្សេងៗពាក់ព័ន្ធជាមួយនឹងអត្ថប្រយោជន៍របបសន្តិសុខសង្គម បងប្អូនអាចទំនាក់ទំនងតាមរយៈលេខទូរសព្ទ Hotline ១២៨៦ ឬតាមបណ្តាញសង្គមផ្លូវការរបស់ ប.ស.ស.៕

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# ពិព័រណ៍ការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ សម្រាប់បងប្អូនអតីតពលករមកពីប្រទេសថៃ យុវជន និងអ្នកស្វែងរកការងារ នៅស្រុកពួក ខេត្តសៀមរាប

## កម្រងរូបភាពសកម្មភាព











នៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២៥ បេឡាជាតិសន្តិសុខសង្គម និង ទីភ្នាក់ងារជាតិមុខរបរ និងការងារ (NEA) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សហការជាមួយសហភាពសហព័ន្ធយុវជនកម្ពុជា និងរដ្ឋបាលខេត្តសៀមរាប បានបន្តរៀបចំ "ពិព័រណ៍ការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ សម្រាប់បងប្អូនអតីតពលករដែលត្រឡប់មកពីប្រទេសថៃ យុវជន និងអ្នកស្វែងរកការងារ" នៅខេត្តសៀមរាប។

ក្នុងកម្មវិធីនេះដែរ **ឯកឧត្តម ហេង សួរ** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានអញ្ជើញជាអធិបតីក្នុងពិធីបើកពិព័រណ៍ការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ សម្រាប់បងប្អូនអតីតពលករដែលត្រឡប់មកពីប្រទេសថៃ ដោយនាំយកឱកាសការងាររាប់ម៉ឺនកន្លែង និងព័ត៌មានស្តីពីអត្ថប្រយោជន៍នៃរបបសន្តិសុខសង្គម ក៏ដូចជាព័ត៌មានស្តីអំពីការបណ្តុះបណ្តាលជំនាញបច្ចេកទេសវិជ្ជាជីវៈដោយឥតគិតថ្លៃផងដែរ។

ថ្លែងក្នុងឱកាសនោះ **ឯកឧត្តមរដ្ឋមន្ត្រី** បានលើកឡើងថា ការធ្វើការងារនៅក្នុងស្រុកមានភាពល្អប្រសើរជាងការធ្វើការនៅប្រទេសថៃ ដូចជាការទទួលបានអត្ថប្រយោជន៍ ប.ស.ស. ដែលរួមមាន ការព្យាបាលជំងឺដោយឥតគិតថ្លៃពេលឈឺ ឬពេលមានគ្រោះថ្នាក់ ទទួលបានប្រាក់សោធន អាចរស់នៅជួបជុំក្រុមគ្រួសារ អាចចូលរួមពិធីបុណ្យប្រពៃណីជាតិនានា ក៏ដូចជាពិធីជួបជុំនានាផងដែរ ហើយម្យ៉ាងទៀតដោយសារយើងជាខ្មែរដូចគ្នា គឺមានភាពងាយស្រួលក្នុងការទំនាក់ទំនង និងយោគយល់គ្នា ជាពិសេសនៅកន្លែងធ្វើការតែម្តង។

សូមបញ្ជាក់ថា កម្មវិធីពិព័រណ៍ខាងលើប្រព្រឹត្តទៅចំនួន២ថ្ងៃ គឺនៅថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០២៥ ធ្វើនៅក្នុងបរិវេណសាលាបឋមសិក្សាសម្តេច ហ៊ុនសែន រណសិរ្សត្រីភូមិ ឃុំដំដែក ស្រុកសូទ្រនិគម និងនៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២៥ ធ្វើនៅក្នុងបរិវេណវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស ពួក ឃុំពួក ស្រុកពួក ខេត្តសៀមរាប ដោយមានអ្នកចូលរួមប្រមាណជាង ២ពាន់នាក់។

ដូច្នេះសម្រាប់បងប្អូនប្រជាពលរដ្ឋខ្មែរទាំងអស់ ជាពិសេសបងប្អូនពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃដែលកំពុងស្វែងរកការងារធ្វើ ឬចង់ផ្លាស់ប្តូរការងារ គឺអាចធ្វើការប្រឹក្សាយោបល់បានភ្លាមៗ ឬក៏អាចសាកសួរព័ត៌មានបន្ថែមតាមរយៈលេខទូរសព្ទ Hotline ១២៩៧។ ដោយឡែកសម្រាប់ចម្ងល់ផ្សេងៗពាក់ព័ន្ធជាមួយនឹងអត្ថប្រយោជន៍របបសន្តិសុខសង្គម បងប្អូនអាចទំនាក់ទំនងតាមរយៈលេខទូរសព្ទ Hotline ១២៨៦ ឬតាមបណ្តាញសង្គមផ្លូវការរបស់ ប.ស.ស.៕

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# ស្វាយរៀង គឺជាខេត្តទី១ ដែលត្រូវបានប្រកាសដាក់ឱ្យអនុវត្តសាកល្បងលើការកែលម្អរថយន្តដឹកជញ្ជូនកម្មករ និយោជិតឱ្យកាន់តែមានផាសុកភាពនិងសុវត្ថិភាព និងត្រួតពិនិត្យលក្ខណៈបច្ចេកទេសរថយន្តដឹកជញ្ជូនកម្មករនិយោជិត

## កម្រងរូបភាពសកម្មភាព


















ស្វាយរៀង គឺជាខេត្តទី១ ដែលត្រូវបានប្រកាសដាក់ឱ្យអនុវត្តសាកល្បងលើការកែលម្អរថយន្តដឹកជញ្ជូនកម្មករនិយោជិតឱ្យកាន់តែមានផាសុកភាពនិងសុវត្ថិភាព និងត្រួតពិនិត្យលក្ខណៈបច្ចេកទេសរថយន្តដឹកជញ្ជូនកម្មករនិយោជិត ដែលពិធីខាងលើនេះប្រព្រឹត្តទៅនៅព្រឹកថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២៥ ស្ថិតក្នុងតំបន់សេដ្ឋកិច្ចពិសេសមេនហាតធេន ក្រុងបាវិត ខេត្តស្វាយរៀង ក្រោមសហអធិបតីភាព **ឯកឧត្តម ហេង សួរ** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និង **ឯកឧត្តម ប៉េង ពោធិ៍នា** រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។ ក្នុងពិធីប្រកាសដាក់ឱ្យអនុវត្តសាកល្បងលើការកែលម្អរថយន្តដឹកជញ្ជូនកម្មករនិយោជិតខាងលើ ក៏មានការអញ្ជើញចូលរួមជាគណៈអធិបតីផងដែរពីសំណាក់ **ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកបេឡាជាតិសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

ថ្លែងក្នុងពិធីខាងលើ **ឯកឧត្តម ហេង សួរ** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបញ្ជាក់ឱ្យដឹងថា ការប្រកាសដាក់ឱ្យអនុវត្តសាកល្បងលើការកែលម្អរថយន្តដឹកជញ្ជូនកម្មករនិយោជិតឱ្យកាន់តែមានផាសុកភាពនិងសុវត្ថិភាព និងត្រួតពិនិត្យលក្ខណៈបច្ចេកទេសរថយន្តដឹកជញ្ជូនកម្មករនិយោជិតនាពេលនេះ គឺជាការផ្សព្វផ្សាយមួយដ៏មានសារៈសំខាន់បំផុត និងអាចជំរុញឱ្យមានការផ្លាស់ប្តូរពីរថយន្តប្រភេទដឹកទំនិញទៅជារថយន្តប្រភេទដឹកអ្នកដំណើរ ឬកែលម្អឱ្យមានកៅអីអង្គុយសមរម្យសម្រាប់ដឹកជញ្ជូនកម្មករនិយោជិត និងដើម្បីលើកកម្ពស់ផាសុកភាព សុវត្ថិភាព និងសណ្តាប់ធ្នាប់ឱ្យកាន់តែប្រសើរជាងមុន ក៏ដូចជាការត្រួតពិនិត្យលក្ខណៈបច្ចេកទេសលើរថយន្តដឹកជញ្ជូនកម្មករនិយោជិតដែលកំពុងបម្រើការងារក្នុងវិស័យវាយនភ័ណ្ឌកាត់ដេរ ផលិតស្បែកជើង ផលិតផលធ្វើដំណើរ និងកាបូបនៅកម្ពុជា។

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

**ឯកឧត្តមរដ្ឋមន្ត្រី** បានបន្តឱ្យដឹងទៀតថា យោងតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា កាលពីថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២៣ កន្លងទៅ បានណែនាំឱ្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អនុវត្តនូវការងារចំពោះមុខសំខាន់ៗរបស់ខ្លួន សំដៅបង្កើនប្រាក់ចំណូល ការធានាលក្ខខណ្ឌការងារល្អប្រសើរ ការពង្រឹងសុខដុមនីយកម្មទំនាក់ទំនងវិជ្ជាជីវៈ កិច្ចគាំពារសង្គម និងជំនាញវិជ្ជាជីវៈ ជូនបងប្អូនកម្មករនិយោជិត និងក្រុមគ្រួសារ ដែលក្នុងនោះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក៏ត្រូវសហការជាមួយភាគីពាក់ព័ន្ធ សិក្សាយន្តការគាំទ្រ និងលើកទឹកចិត្តឱ្យមានការផ្លាស់ប្តូរជាបណ្តើរៗ នូវមធ្យោបាយដឹកជញ្ជូនកម្មករនិយោជិតឱ្យកាន់តែមានផាសុកភាពជាងមុន ត្រឹមឆ្នាំ២០២៧ និងត្រូវរកដំណោះស្រាយណាដែលជួយធានាសុវត្ថិភាពក្នុងការដឹកជញ្ជូនកម្មករនិយោជិត ហើយការគិតគូរនេះមិនត្រឹមតែគិតដល់កម្មករនិយោជិតទេ គឺបានគិតទៅដល់បងប្អូនជាអ្នកបើកបររថយន្តដឹកជញ្ជូនកម្មករនិយោជិត ដែលត្រូវថែរក្សាអាជីព និងផលប្រយោជន៍របស់ពួកគាត់ ព្រមទាំងរកដំណោះស្រាយល្អៗផងដែរ។ ដែលទាំងនេះ សបញ្ជាក់ឱ្យឃើញថា រាជរដ្ឋាភិបាលកម្ពុជា ពិតជាបានគិតគូរគ្រប់ជ្រុងជ្រោយចំពោះបងប្អូនកម្មករនិយោជិត មិនគ្រាន់តែពេលកំពុងធ្វើការ ឬមានបញ្ហាសុខភាពនោះទេ សូម្បីតែពេលបងប្អូនកម្មករនិយោជិតធ្វើដំណើរ ក៏ជាក្តីកង្វល់របស់រាជរដ្ឋាភិបាលផងដែរ។

ក្នុងឱកាសជាមួយគ្នានេះ **ឯកឧត្តម ប៉េង ពោធិ៍នា** រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន ក៏បានធ្វើការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលមាន ប.ស.ស. ជាសេនាធិការ ក៏ដូចជាក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធនានា ដែលកន្លងមក រហូតមកដល់ពេលនេះ បានអនុវត្តការងារយ៉ាងសកម្មចំពោះសុខសុវត្ថិភាពក្នុងការធ្វើដំណើរទាំងទៅទាំងមករបស់បងប្អូនកម្មករនិយោជិត ហើយក្រសួងសាធារណការនិងដឹកជញ្ជូន នឹងបង្កើនកិច្ចសហការជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក៏ដូចជាក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនានាបន្ថែមទៀត ក្នុងន័យរួមចំណែកកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍មកលើបងប្អូនកម្មករនិយោជិត ឱ្យមកនៅកម្រិតទាបបំផុត។

សូមបញ្ជាក់ថា ពិធីប្រកាសដាក់ឱ្យអនុវត្តសាកល្បងលើការកែលម្អរថយន្តដឹកជញ្ជូនកម្មករនិយោជិតឱ្យកាន់តែមានផាសុកភាព និងសុវត្ថិភាព និងត្រួតពិនិត្យលក្ខណៈបច្ចេកទេសរថយន្តដឹកជញ្ជូនកម្មករនិយោជិតខាងលើ មានការចូលរួមពីសំណាក់បងប្អូនអ្នកបើកបររថយន្តដឹកជញ្ជូនកម្មករនិយោជិតក្នុងខេត្តស្វាយរៀងសរុបប្រមាណជា ៧០០ នាក់។

## កម្រងរូបភាពសកម្មភាព



© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# វគ្គបណ្តុះបណ្តាលស្តីពី "បច្ចេកទេសអធិការកិច្ចសន្តិសុខសង្គម មូលដ្ឋានសុខាភិបាល និងបទប្បញ្ញត្តិពាក់ព័ន្ធ"

## កម្រងរូបភាពសកម្មភាព










នាព្រឹកថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២៥ **ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានអញ្ជើញជាគណៈអធិបតីក្នុងពិធីបើកវគ្គបណ្តុះបណ្តាលស្តីពី "បច្ចេកទេសអធិការកិច្ចសន្តិសុខសង្គម មូលដ្ឋានសុខាភិបាល និងបទប្បញ្ញត្តិពាក់ព័ន្ធ" ក្រោមអធិបតីភាព **ឯកឧត្តម អ៊ិន ខេមរា** រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ហេង សួរ** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជូនដល់ថ្នាក់ដឹកនាំសាខា ប.ស.ស. ខេត្ត-ខណ្ឌ មន្ត្រី និងបុគ្គលិកក្រោមឱវាទ ប.ស.ស. ប្រមាណជិត ២០០រូប។

វគ្គបណ្តុះបណ្តាលខាងលើ រៀបចំឡើងក្នុងគោលបំណងដើម្បីបណ្តុះបណ្តាលដល់ក្រុមការងារអធិការសន្តិសុខសង្គម និងមន្ត្រីមូលដ្ឋានសុខាភិបាលទូទាំងរាជធានីខេត្ត ដើម្បីលើកកម្ពស់សមត្ថភាព និងការយល់ដឹង អំពីបច្ចេកទេសក្នុងការចុះអធិការកិច្ចសន្តិសុខសង្គម និងបច្ចេកទេសត្រួតពិនិត្យមូលដ្ឋានសុខាភិបាល ព្រមទាំងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដើម្បីបំពេញតួនាទីភារកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព ជាពិសេសការចាត់វិធានការណែនាំ ការផ្តល់ដំបូន្មាន ឬការពិន័យអន្តរការណ៍ ចំពោះនីតិបុគ្គល ឬរូបវន្តបុគ្គល ដែលប្រព្រឹត្តអំពើល្មើសច្បាប់ស្តីពីរបបសន្តិសុខសង្គម ធានាសិទ្ធិ និងអត្ថប្រយោជន៍ស្របច្បាប់របស់កម្មករនិយោជិត ជាសមាជិក ប.ស.ស. ក្នុងវិស័យសន្តិសុខសង្គម បានអនុវត្ត។

សូមបញ្ជាក់ថា វគ្គបណ្តុះបណ្តាលនេះ រៀបចំដោយវិទ្យាស្ថានជាតិការងារ សហការជាមួយបេឡាជាតិសន្តិសុខង្គម នៅស្នាក់ការកណ្តាល ប.ស.ស. រាជធានីភ្នំពេញ៕

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# វិទ្យាស្ថានជាតិការងារ និង បេឡាជាតិសន្តិសុខសង្គម នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានសហការគ្នារៀបចំវគ្គបណ្តុះបណ្តាលស្តីពី "បច្ចេកទេសអធិការកិច្ចសន្តិសុខសង្គម មូលដ្ឋានសុខាភិបាល និងបទប្បញ្ញត្តិពាក់ព័ន្ធ" ជាលើកទី២

## កម្រងរូបភាពសកម្មភាព










នាព្រឹកថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២៥ **ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានអញ្ជើញជាគណៈអធិបតីបើកវគ្គបណ្តុះបណ្តាលស្តីពី "បច្ចេកទេសអធិការកិច្ចសន្តិសុខសង្គម មូលដ្ឋានសុខាភិបាល និងបទប្បញ្ញត្តិពាក់ព័ន្ធ" ក្រោមអធិបតីភាព **ឯកឧត្តម អ៊ិន ខេមរា** រដ្ឋលេខាធិការ តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ហេង សួរ** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជូនដល់ថ្នាក់ដឹកនាំសាខា ប.ស.ស. ខេត្ត-ខណ្ឌ មន្ត្រី និងបុគ្គលិកក្រោមឱវាទ ប.ស.ស.។ នេះគឺជាលើកទី២ ហើយដែលអង្គភាពទាំងពីរបានសហការគ្នារៀបចំវគ្គបណ្តុះបណ្តាលនេះឡើង។

វគ្គបណ្តុះបណ្តាលខាងលើ រៀបចំឡើងក្នុងគោលបំណងដើម្បីបណ្តុះបណ្តាលដល់ក្រុមការងារអធិការសន្តិសុខសង្គម និងមន្ត្រីមូលដ្ឋានសុខាភិបាលទូទាំងរាជធានីខេត្ត ដើម្បីលើកកម្ពស់សមត្ថភាព និងការយល់ដឹង អំពីបច្ចេកទេសក្នុងការចុះអធិការកិច្ចសន្តិសុខសង្គម និងបច្ចេកទេសត្រួតពិនិត្យមូលដ្ឋានសុខាភិបាល ព្រមទាំងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដើម្បីបំពេញតួនាទីភារកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព ជាពិសេសការចាត់វិធានការណែនាំ ការផ្តល់ដំបូន្មាន ឬការពិន័យអន្តរការណ៍ ចំពោះនីតិបុគ្គល ឬរូបវន្តបុគ្គល ដែលប្រព្រឹត្តអំពើល្មើសច្បាប់ស្តីពីរបបសន្តិសុខសង្គម ធានាសិទ្ធិ និងអត្ថប្រយោជន៍ស្របច្បាប់របស់កម្មករនិយោជិត ជាសមាជិក ប.ស.ស. ក្នុងវិស័យសន្តិសុខសង្គមបានអនុវត្ត។

សូមបញ្ជាក់ថា វគ្គបណ្តុះបណ្តាលនេះ ប្រព្រឹត្តទៅនៅស្នាក់ការកណ្តាល ប.ស.ស. រាជធានីភ្នំពេញ ដោយមានអ្នកចូលរួមប្រមាណជាង ១០០រូប៕

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# ប.ស.ស. បើកពិធីផ្សព្វផ្សាយស្តីពី "អត្ថប្រយោជន៍របបសន្តិសុខសង្គម" ជូនសោធនិក អ្នកបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ អ្នកទទួលបានធនលាភឧត្តរជីវី និងអ្នកត្រៀមចូលនិវត្តន៍

## កម្រងរូបភាពសកម្មភាព










នាព្រឹកថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៥ អ្នកទទួលផល ដែលជាសោធនិក អ្នកបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ អ្នកទទួលបានធនលាភឧត្តរជីវី និងអ្នកត្រៀមចូលនិវត្តន៍ នៅរាជធានីភ្នំពេញ ប្រមាណជា ៣០០រូប បានអញ្ជើញចូលរួមពិធីសំណេះសំណាល និងផ្សព្វផ្សាយស្តីពី "អត្ថប្រយោជន៍របបសន្តិសុខសង្គម" ជូនសោធនិក អ្នកបាត់បង់សមត្ថភាពការងារអចិន្ត្រៃយ៍ អ្នកទទួលបានធនលាភឧត្តរជីវី និងអ្នកត្រៀមចូលនិវត្តន៍ ដែលប្រព្រឹត្តទៅក្រោមអធិបតីភាព **ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅទីស្នាក់ការកណ្តាល ប.ស.ស. រាជធានីភ្នំពេញ។

មានប្រសាសន៍ក្នុងពិធីសំណេះសំណាល **ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល** បានស្វាគមន៍យ៉ាងកក់ក្តៅចំពោះ វត្តមានបងប្អូនដែលទទួលផល ជាពិសេសបងប្អូនជាសោធនិក ដែលបានទទួលប្រាក់ឧបត្ថម្ភប្រចាំខែ ទាំងនេះជាសមិទ្ធផលប្រវត្តិសាស្ត្រដែលបង្កើតដោយសម្តេចតេជោ នឹងបច្ចុប្បន្នត្រូវបានអនុវត្តបន្តក្រោមការដឹកនាំប្រកបដោយភាពឈ្លាសវៃរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។

**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល** បានគូសបញ្ជាក់ថា ការរឹងមាំ និងរីកចម្រើននៃប្រព័ន្ធសន្តិសុខសង្គម គឺកើតចេញពីគោលនយោបាយ និងយុទ្ធសាស្ត្រលើការអភិវឌ្ឍសេដ្ឋកិច្ចជាតិ របស់ប្រមុខរាជរដ្ឋាភិបាល ដែលតែងតែយកចិត្តទុកដាក់ និងលើកកម្ពស់សុខុមាលភាព និងជីវភាពរស់នៅរបស់កម្មករនិយោជិត។ ទន្ទឹមនេះ សូមបងប្អូនប្រជាពលរដ្ឋចូលរួមបន្តគាំទ្ររាជរដ្ឋាភិបាល ដើម្បីធានាបាននូវសន្តិភាព ស្ថិរភាព និងប្រព័ន្ធសន្តិសុខសង្គមយូរអង្វែងសម្រាប់ប្រទេសជាតិនាពេលអនាគតផងដែរ។

ឆ្លៀតក្នុងឱកាសនោះ **ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល** បានអំពាវនាវដល់បងប្អូនប្រជាពលរដ្ឋទាំងអស់ សូមចូលរួមជាមួយរដ្ឋាភិបាលប្រឆាំងជាមួយនឹងការឈ្លានពានទឹកដី តាមរយៈស្មារតីសាមគ្គីជាតិ ការចូលរួមគាំទ្រកម្លាំងកាយ កម្លាំងចិត្ត និងធនធាន ដើម្បីលើកទឹកចិត្តដល់កងទ័ពជួរមុខ ដែលកំពុងបំពេញភារកិច្ចការពារជាតិ និងរក្សាបូរណភាពទឹកដីនៅតាមបណ្តាព្រំដែនមួយចំនួន ដែលកំពុងតានតឹងផងដែរ។

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# ឯកឧត្តមបណ្ឌិត ហេង សុផាន់ណារិទ្ធ អញ្ជើញជាអធិបតីក្នុងពិធីបិទវគ្គបណ្តុះបណ្តាល និងការចែកវិញ្ញាបនបត្រជូនសិក្ខាកាម ចូលរួមវគ្គបណ្តុះបណ្តាលក្រោមការឧបត្ថម្ភគាំទ្រដោយកិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ (GIZ)

## កម្រងរូបភាពសកម្មភាព

















នាព្រឹកថ្ងៃទី២ ខែធ្នូ ឆ្នាំ២០២៥ បេឡាជាតិសន្តិសុខសង្គម ប.ស.ស. បានរៀបចំពិធីបិទវគ្គបណ្តុះបណ្តាល និងការចែកវិញ្ញាបនបត្រជូនសិក្ខាកាម ចូលរួមវគ្គបណ្តុះបណ្តាលក្រោមការឧបត្ថម្ភគាំទ្រដោយកិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ (GIZ) ដែលប្រព្រឹត្តទៅក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិត ហេង សុផាន់ណារិទ្ធ** អគ្គនាយករង ប.ស.ស. តំណាង **ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅស្នាក់ការកណ្តាល ប.ស.ស. រាជធានីភ្នំពេញ ដោយមានការចូលរួមពីថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិក ប.ស.ស. និងតំណាងកិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ (GIZ) ចំនួន១៤០រូប។

ក្នុងឱកាសនោះដែរ **ឯកឧត្តមបណ្ឌិតអគ្គនាយករង** បានថ្លែងដោយក្តីជឿជាក់ថា សិក្ខាកាមទាំងអស់នឹងយកចំណេះដឹង និងបទពិសោធន៍ល្អៗ ដែលទទួលបានពីវគ្គបណ្តុះបណ្តាលនេះ យកទៅអភិវឌ្ឍលើការងារប្រចាំថ្ងៃឱ្យកាន់តែប្រសើរ និងប្រកបដោយភាពច្នៃប្រឌិត ព្រមទាំងបន្តចែករំលែកចំណេះដឹងទៅដល់មន្ត្រី និងបុគ្គលិកនៅតាមនាយកដ្ឋានរបស់ខ្លួនឱ្យកាន់តែទូលំទូលាយបន្ថែមទៀត។

ឆ្លៀតក្នុងឱកាសនោះដែរ **ឯកឧត្តមបណ្ឌិតអគ្គនាយករង** ប.ស.ស. ក៏បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ លោកគ្រូឧទ្ទេស និងកិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ (GIZ) ដែលតែងតែផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ ដល់ ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍធនធានមនុស្ស និងពង្រឹងស្ថាប័ន ប.ស.ស. ទាំងមូល។

សូមបញ្ជាក់ថា៖ បន្ទាប់ពីបញ្ចប់វគ្គបណ្តុះបណ្តាល **ឯកឧត្តមបណ្ឌិតអគ្គនាយករង** បានផ្តល់កិត្តិយសអញ្ជើញប្រគល់វិញ្ញាបនបត្រដោយផ្ទាល់ជូនដល់សិក្ខាកាមទាំងអស់ដែលបានចូលរួមវគ្គបណ្តុះបណ្តាលនេះផងដែរ៕

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# ប.ស.ស. បន្តផ្សព្វផ្សាយអំពីការអនុវត្តរបបសន្តិសុខសង្គម ផ្នែកថែទាំសុខភាព ដល់សិស្សនាយនគរបាល និងនាយនគរបាលរងជំនាន់ទី១៩ លើកទី២ នៅខេត្តបាត់ដំបង

## កម្រងរូបភាពសកម្មភាព













នាព្រឹកថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២៥ **ឯកឧត្តមបណ្ឌិត ហេង សុផាន់ណារិទ្ធ** អគ្គនាយករង ប.ស.ស. តំណាង **ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និង **លោកវរសេនីយ៍ឯក ឈួន សុវណ្ណារ័ត្ន** នាយកសាលានគរបាលជាតិភូមិភាគ៥ បានអញ្ជើញជាសហាធិបតីបើកពិធីផ្សព្វផ្សាយស្តីពី ការអនុវត្តរបបសន្តិសុខសង្គម ផ្នែកថែទាំសុខភាព ជូនដល់សិស្សនាយនគរបាល និងនាយនគរបាល នៃសាលានគរបាលជាតិភូមិភាគ៥ ដែលស្ថិតក្នុងទឹកដីខេត្តបាត់ដំបង ដោយមានអ្នកចូលរួមសរុបចំនួន ១៨៧រូប។

ក្នុងពិធីផ្សព្វផ្សាយនេះ **ឯកឧត្តមបណ្ឌិតអគ្គនាយករង** បានបញ្ជាក់ថា ការផ្តល់ការថែទាំសុខភាពដល់សិស្សនាយនគរបាល និងនាយនគរបាល គឺជាការយកចិត្តទុកដាក់ខ្ពស់បំផុតពីប្រមុខរាជរដ្ឋាភិបាល ក្នុងការពង្រីកវិសាលភាព នៃការអនុវត្តរបបសន្តិសុខសង្គម ផ្នែកថែទាំសុខភាពសម្រាប់សិស្សនាយនគរបាល និងនាយនគរបាល នៅពេលមានបញ្ហាសុខភាព មាតុភាព ឬគ្រោះថ្នាក់ផ្សេងៗជាយថាហេតុ ក្នុងអំឡុងពេលកំពុងសិក្សា និងទទួលបានសេវាពិនិត្យ និងព្យាបាលដោយឥតគិតថ្លៃតាមរយៈ ប.ស.ស. ដែលសបញ្ជាក់អំពីឆន្ទៈ និងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ក្នុងការអនុវត្តយុទ្ធសាស្ត្រគាំពារសង្គម ដើម្បីសម្រេចបានកម្មវិធីអាទិភាព១ នៃយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ក្នុងការផ្តល់ការថែទាំសុខភាពឆ្ពោះទៅកម្មវិធីគ្របដណ្តប់សុខភាពជាសកល។

ក្នុងឱកាសជាមួយគ្នានេះ **លោកវរសេនីយ៍ឯក ឈួន សុវណ្ណារ័ត្ន** នាយកសាលានគរបាលជាតិភូមិភាគ៥ បានថ្លែងអំណរគុណចំពោះការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល និង ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលបានអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ស្តីពីការអនុវត្តរបបសន្តិសុខសង្គម ផ្នែកថែទាំសុខភាពបានយ៉ាងសកម្ម និងរៀបចំបទបង្ហាញយ៉ាងលម្អិត និងមានសារៈសំខាន់ ដើម្បីឱ្យថ្នាក់ដឹកនាំ និងសិស្សនាយនគរបាល និងនាយនគរបាលរង នៅសាលានគរបាលជាតិភូមិភាគ៥ បានយល់ដឹងកាន់តែច្បាស់ពីអត្ថប្រយោជន៍ និងសិទ្ធិដែលត្រូវទទួលបានពី ប.ស.ស.៕

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# ឯកឧត្តមបណ្ឌិត ហេង សុផាន់ណារិទ្ធ
# អញ្ជើញចូលរួមកិច្ចប្រជុំក្រុមការងារអន្តរក្រសួងរៀបចំសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច

## កម្រងរូបភាពសកម្មភាព











នាព្រឹកថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២៥ **ឯកឧត្តមបណ្ឌិត ហេង សុផាន់ណារិទ្ធ** អគ្គនាយករង ប.ស.ស. និងជាសមាជិកក្រុមការងារអន្តរក្រសួងរៀបចំសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច តំណាង **ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានដឹកនាំមន្ត្រីជំនាញ ប.ស.ស. អម **ឯកឧត្តម ជា កុសល** រដ្ឋលេខាធិការ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចូលរួមកិច្ចប្រជុំក្រុមការងារអន្តរក្រសួងរៀបចំសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច នៅសាលប្រជុំ អគារ "ឃ" នៃទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

កិច្ចប្រជុំនេះ ប្រព្រឹត្តទៅក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិត គង់ ម៉ារី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល និងជាប្រធានក្រុមការងារអន្តរក្រសួង ដែលមានសមាជិកចូលរួមមកពីក្រសួង-ស្ថាប័នសរុបប្រមាណជា ១៥០នាក់ ក្នុងគោលបំណងដើម្បីពិនិត្យលើវឌ្ឍនភាពការងារ និងកំណត់ទិសដៅការងារអនុវត្តបន្តសម្រាប់ឆ្នាំ២០២៦ ក៏ដូចជាពិនិត្យលើផែនការសកម្មភាពសម្រាប់ការអនុវត្តយុទ្ធសាស្ត្រស្តីពី ការអភិវឌ្ឍសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច ឆ្នាំ ២០២៥-២០២៨ ដែលត្រូវបានដាក់ឱ្យអនុវត្តជាផ្លូវការ កាលពីថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៥ ដែលជាផែនទីបង្ហាញផ្លូវដ៏មុតស្រួចសម្រាប់ក្រសួង ស្ថាប័ន ក្នុងការកែទម្រង់ការផ្តល់សេវាសាធារណៈក្នុង ក្របខ័ណ្ឌធុរកិច្ចឱ្យកាន់តែមានប្រសិទ្ធភាព និងតម្លាភាព៕

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# វគ្គបណ្តុះបណ្តាលស្តីពី "បច្ចេកទេសអធិការកិច្ចសន្តិសុខសង្គម មូលដ្ឋានសុខាភិបាល និងបទប្បញ្ញត្តិពាក់ព័ន្ធ" ត្រូវបានបញ្ចប់ដោយជោគជ័យ

## កម្រងរូបភាពសកម្មភាព



នារសៀលថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២៥ **ឯកឧត្តម ម៉ែន នះខុធ** អគ្គនាយករង ប.ស.ស. តំណាង **ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានអញ្ជើញជាគណៈអធិបតីបិទវគ្គបណ្តុះបណ្តាលស្តីពី បច្ចេកទេសអធិការកិច្ចសន្តិសុខសង្គម មូលដ្ឋានសុខាភិបាល និងបទប្បញ្ញត្តិពាក់ព័ន្ធ ដែលត្រូវបានបញ្ចប់ដោយជោគជ័យ ក្រោមអធិបតីភាព **ឯកឧត្តម អ៊ិន ខេមរា** រដ្ឋលេខាធិការ តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ហេង សួរ** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នៅស្នាក់ការកណ្តាល ប.ស.ស. រាជធានីភ្នំពេញ ដោយមានការចូលរួមពីថ្នាក់ដឹកនាំសាខា ប.ស.ស. ខេត្ត-ខណ្ឌ មន្ត្រី និងបុគ្គលិកក្រោមឱវាទ ប.ស.ស. សរុបប្រមាណជាង ១០០រូប។

មានប្រសាសន៍ក្នុងពិធីបិទវគ្គបណ្តុះបណ្តាលខាងលើ **ឯកឧត្តមរដ្ឋលេខាធិការ** បានកោតសរសើរ និងថ្លែងអំណរគុណដល់សិក្ខាកាមទាំងអស់ ដែលបានចំណាយពេលវេលា ចូលរួមសិក្សាក្នុងវគ្គបណ្តុះបណ្តាលស្តីពី "បច្ចេកទេសអធិការកិច្ចសន្តិសុខសង្គម មូលដ្ឋានសុខាភិបាល និងបទប្បញ្ញត្តិពាក់ព័ន្ធ" រយៈពេលបីថ្ងៃ ប្រកបដោយការយកចិត្តទុកដាក់ ពិសេសប្រតិបត្តិតាមអង្គទាំង៤ "ស្តាប់ គិត សួរ កត់ត្រា" ដោយទទួលបានលទ្ធផលជាទីមោទនៈ។

**ឯកឧត្តមរដ្ឋលេខាធិការ** សង្ឃឹម និងជឿជាក់ថា សិក្ខាកាមទាំងអស់ ប្រាកដជានឹងយកចំណេះដឹងដែលទទួលបានពីវគ្គបណ្តុះបណ្តាលនេះ ទៅពង្រឹងសមត្ថភាពខ្លួន និងអង្គភាព ព្រមទាំងបន្តផ្សព្វផ្សាយនូវបទប្បញ្ញត្តិពាក់ព័ន្ធទាំងនេះ ឱ្យកាន់តែប្រសើរថែមទៀតជាក់ជាមិនខាន៕

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# ឯកឧត្តម គឹម កែវរស្មី បានដឹកនាំមន្ត្រីជំនាញ ប.ស.ស. ចូលរួម ប្រជុំជាមួយអគ្គលេខាធិការ នៃអាជ្ញាធរសវនកម្មជាតិ

## កម្រងរូបភាពសកម្មភាព










នៅថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២៥ **ឯកឧត្តម គឹម កែវរស្មី** អគ្គនាយករង ប.ស.ស. តំណាង **ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយក ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានដឹកនាំមន្ត្រីជំនាញនៃនាយកដ្ឋានគ្រប់គ្រងថវិកាហិរញ្ញវត្ថុ និងគណនេយ្យ ចូលរួមប្រជុំជាមួយអគ្គលេខាធិការ នៃអាជ្ញាធរសវនកម្មជាតិ ស្តីពី "ការបិទវគ្គសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់បេឡាជាតិសន្តិសុខសង្គមសម្រាប់ការិយបរិច្ឆេទ ២០២៤ និងឆ្នាំពាក់ព័ន្ធ" ។

កិច្ចប្រជុំនេះ ប្រព្រឹត្តទៅដោយផ្ទាល់នៅទីស្នាក់ការកណ្តាល ប.ស.ស. រាជធានីភ្នំពេញ ដោយមានការចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃ ប.ស.ស. និងតំណាងអគ្គលេខាធិការ នៃអាជ្ញាធរសវនកម្មជាតិ សរុបប្រមាណ ២៥រូប៕

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# ឯកឧត្តម គឹម កែវរស្មី ដឹកនាំនាយកដ្ឋានជំនាញ ចូលរួមប្រជុំពិភាក្សាជាមួយ គណៈប្រតិភូអធិការកិច្ចហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## កម្រងរូបភាពសកម្មភាព

















នាព្រឹកថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២៥ **ឯកឧត្តម គឹម កែវរស្មី** អគ្គនាយករង ប.ស.ស. តំណាង **ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានដឹកនាំនាយកដ្ឋានជំនាញ ចូលរួមប្រជុំពិភាក្សាជាមួយគណៈប្រតិភូអធិការកិច្ចហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅស្នាក់ការកណ្តាល ប.ស.ស.រាជធានីភ្នំពេញ ដោយមានអ្នកចូលរួមប្រមាណជា ២០រូប។

កិច្ចប្រជុំពិភាក្សានេះ រៀបចំឡើងក្នុងគោលបំណងដើម្បីធ្វើអធិការកិច្ចហិរញ្ញវត្ថុលើការគ្រប់គ្រងការអនុវត្តចំណូល-ចំណាយថវិការដ្ឋ ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ក្នុងការិយបរិច្ឆេទ២០២៤ និងឆ្នាំពាក់ព័ន្ធ។

ក្នុងឱកាសនោះដែរ **ឯកឧត្តមអគ្គនាយករង** ប.ស.ស. បានស្នើដល់នាយកដ្ឋានជំនាញទាំងអស់ ត្រូវសហការសម្របសម្រួលជាមួយគណៈប្រតិភូអធិការកិច្ចហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីឱ្យកិច្ចការអធិការកិច្ចនេះដំណើរការទៅដោយរលូន និងមានប្រសិទ្ធភាព៕

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# កិច្ចប្រជុំពិភាក្សា និងផ្តល់ធាតុចូលពាក់ព័ន្ធនឹងការអនុវត្តស្តង់ដាគណនេយ្យសាធារណៈ សម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលជាស្ថាប័នប្រតិបត្តិករតែមួយគត់ធ្វើប្រតិបត្តិការរបបសន្តិសុខសង្គម ក្នុងអង្គភាព ប.ស.ស.

## កម្រងរូបភាពសកម្មភាព



នាព្រឹកថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២៥នេះ **ឯកឧត្តម គឹម កែវរស្មី** អគ្គនាយករង ប.ស.ស. តំណាង **ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានដឹកនាំមន្ត្រីបច្ចេកទេសចូលរួមកិច្ចប្រជុំពិភាក្សា និងផ្តល់ធាតុចូលពាក់ព័ន្ធនឹងការអនុវត្តស្តង់ដាគណនេយ្យសាធារណៈ សម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលជាស្ថាប័នប្រតិបត្តិករតែមួយគត់ធ្វើប្រតិបត្តិការរបបសន្តិសុខសង្គម នៅស្នាក់ការកណ្តាល ប.ស.ស. រាជធានីភ្នំពេញ ដោយមានអ្នកចូលរួមប្រមាណជាង៥០រូប មកពីតំណាង៩ស្ថាប័ន/អង្គភាព។

ក្នុងឱកាសនោះដែរ **ឯកឧត្តមអគ្គនាយករង** ប.ស.ស. បានថ្លែងនូវការស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមានសមាជិក សមាជិកានៃអង្គប្រជុំទាំងអស់ ដែលបានចំណាយពេលវេលាដ៏មានតម្លៃចូលរួមក្នុងកិច្ចប្រជុំនេះ ដើម្បីពង្រឹងយន្តការការងារគណនេយ្យឱ្យកាន់តែមានប្រសិទ្ធភាព។ តាមរយៈកិច្ចប្រជុំនេះដែរ សមាជិក សមាជិកា បានផ្តល់នូវមតិយោបល់ និងធាតុចូលបច្ចេកទេសយ៉ាងសំខាន់ៗ ដើម្បីសម្រេចឱ្យបាននូវក្របខ័ណ្ឌស្តង់ដាគណនេយ្យមួយដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងសុក្រឹតភាពសម្រាប់ ប.ស.ស.។

ជាទីបញ្ចប់ **ឯកឧត្តមអគ្គនាយករង** ប.ស.ស. បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះការផ្តល់ជាធាតុចូលដ៏មានសារៈសំខាន់ពីសំណាក់តំណាងស្ថាប័ន/អង្គភាពទាំងអស់ ដែលនេះជាមូលដ្ឋានគ្រឹះដ៏រឹងមាំក្នុងការរៀបចំប្រព័ន្ធគណនេយ្យ ប.ស.ស. ឱ្យកាន់តែមានភាពទំនើប និងអនុលោមតាមស្តង់ដាដែលបានកំណត់ ស្របតាមលិខិតបទដ្ឋានគតិយុត្តិជាធរមាន៕

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# ឯកឧត្តម យុន ចាន់ណារិទ្ធ ដឹកនាំនាយកដ្ឋានជំនាញពាក់ព័ន្ធ នៃបេឡាជាតិសន្តិសុខសង្គម ជួបប្រជុំជាមួយនិយ័តករសន្តិសុខសង្គម ដើម្បីស្រាយបំភ្លឺការអនុវត្តអនុក្រឹត្យស្តីពី "មូលដ្ឋានគោលនៃភាពរឹងមាំផ្នែកហិរញ្ញវត្ថុ នៃមូលនិធិសន្តិសុខសង្គម"

## កម្រងរូបភាពសកម្មភាព

















នៅថ្ងៃទី២ ខែធ្នូ ឆ្នាំ២០២៥ **ឯកឧត្តម យុន ចាន់ណារិទ្ធ** អគ្គនាយករង ប.ស.ស. តំណាង **ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកបេឡាជាតិសន្តិសុខសង្គម ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានដឹកនាំនាយកដ្ឋានជំនាញពាក់ព័ន្ធនៃ ប.ស.ស. ចូលរួមកិច្ចប្រជុំកម្រិតបច្ចេកទេសជាមួយតំណាងនិយ័តករសន្តិសុខសង្គម ន.ស.ស. ដែលដឹកនាំដោយ លោក ឡេង សុខឡុង ប្រធាននាយកដ្ឋាននៃនិយ័តករសន្តិសុខសង្គម ដើម្បីស្រាយបំភ្លឺអំពីការអនុវត្តអនុក្រឹត្យលេខ១៧២ អនក្រ.បក ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២៥ ស្តីពី "មូលដ្ឋានគោលនៃភាពរឹងមាំផ្នែកហិរញ្ញវត្ថុនៃមូលនិធិសន្តិសុខសង្គម" ដោយមានអ្នកចូលរួមប្រមាណជាង ៣០រូប នៅស្នាក់ការកណ្តាល ប.ស.ស. រាជធានីភ្នំពេញ។

កិច្ចប្រជុំនេះ មានគោលបំណងពិភាក្សា និងបំភ្លឺកម្រិតបច្ចេកទេសដែលឆ្លុះបញ្ចាំងពីប្រតិបត្តិការហិរញ្ញវត្ថុជាក់ស្តែងរបស់ ប.ស.ស. ស្របតាមអនុក្រឹត្យលេខ១៧២អនក្រ.បក ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២៥ ស្តីពី "មូលដ្ឋានគោលនៃភាពរឹងមាំផ្នែកហិរញ្ញវត្ថុនៃមូលនិធិសន្តិសុខសង្គម" ដែលគ្រោងនឹងដាក់ឱ្យ ប.ស.ស. អនុវត្តនៅដើមឆ្នាំ២០២៦ ។

កិច្ចប្រជុំរវាង បេឡាជាតិសន្តិសុខសង្គម និងនិយ័តករសន្តិសុខសង្គម បានឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តខ្ពស់របស់ស្ថាប័នទាំងពីរ ក្នុងការអនុវត្តលក្ខខណ្ឌគតិយុត្តនានាពាក់ព័ន្ធនឹងហិរញ្ញវត្ថុនៃមូលនិធិសន្តិសុខសង្គម ត្រូវបានអនុវត្តបានត្រឹមត្រូវ ច្បាស់លាស់ និងមានតម្លាភាព ដើម្បីរក្សានូវនិរន្តរភាព និងផលប្រយោជន៍របស់សមាជិក ប.ស.ស.។

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# ឯកឧត្តម យុន ចាន់ណារិទ្ធ អញ្ជើញជាអធិបតីភាពបើកកិច្ចប្រជុំពិភាក្សាទ្វេភាគីជាមួយជនបង្គោល សម្រាប់ការធ្វើបច្ចុប្បន្នភាព "សៀវភៅណែនាំស្តីពីយន្តការតាមដាន និងវាយតម្លៃប្រព័ន្ធគាំពារសង្គម"

## កម្រងរូបភាពសកម្មភាព










នាព្រឹកថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៥ **ឯកឧត្តម យុន ចាន់ណារិទ្ធ** អគ្គនាយករង ប.ស.ស. តំណាង **ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានអញ្ជើញជាអធិបតីភាពបើកកិច្ចប្រជុំពិភាក្សាទ្វេភាគីជាមួយជនបង្គោល សម្រាប់ការធ្វើបច្ចុប្បន្នភាព "សៀវភៅណែនាំស្តីពីយន្តការតាមដាន និងវាយតម្លៃប្រព័ន្ធគាំពារសង្គម" ។

កិច្ចប្រជុំពិភាក្សាខាងលើ រៀបចំឡើងក្នុងគោលបំណងប្រមូលធាតុចូលពីអង្គភាពរាយការណ៍ក្នុងយន្តការតាមដាន និងវាយតម្លៃប្រព័ន្ធគាំពារសង្គម និងក្រសួងស្ថាប័នពាក់ព័ន្ធទាំងអស់ ដើម្បីធ្វើបច្ចុប្បន្នកម្មសៀវភៅណែនាំស្តីពីយន្តការតាមដាន និងវាយតម្លៃប្រព័ន្ធគាំពារសង្គម ដែលបានដាក់ឱ្យអនុវត្តតាំងពីឆ្នាំ២០២១ ឱ្យឯកសារនេះមានលក្ខណៈគ្រប់ជ្រុងជ្រោយ។

ជាមួយគ្នានោះ **ឯកឧត្តមអគ្គនាយករង** ប.ស.ស. បានផ្តល់ជាអនុសាសន៍មួយចំនួនដល់សមាជិក សមាជិកា នៃអង្គប្រជុំពិភាក្សា សូមចូលរួមបញ្ចេញមតិឱ្យបានផុសផុល ដើម្បីឱ្យសៀវភៅណែនាំស្តីពីយន្តការតាមដាន និងវាយតម្លៃប្រព័ន្ធគាំពារសង្គមមានលក្ខណៈគ្រប់គ្រាន់ពេញលេញ និងសមស្របនឹងស្ថានភាពបច្ចុប្បន្ន។

សូមបញ្ជាក់ថា កិច្ចប្រជុំពិភាក្សានេះ ប្រព្រឹត្តទៅនៅស្នាក់ការកណ្តាល ប.ស.ស. រាជធានីភ្នំពេញ ដោយមានការចូលរួមពីតំណាងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម និងមន្ត្រីបច្ចេកទេស ប.ស.ស. ប្រមាណជាង ៣០រូប៕

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# ឯកឧត្តម យុន ចាន់ណារិទ្ធ អញ្ជើញចូលរួមធ្វើបទបង្ហាញ និងធ្វើជាវាគ្មិនក្នុងកិច្ចពិភាក្សាពិសេសនៃសន្និសីទថ្នាក់ជាតិ ស្តីពីសេដ្ឋកិច្ចការងារ ឆ្នាំ២០២៥

## កម្រងរូបភាពសកម្មភាព












នៅរសៀលថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២៥ **ឯកឧត្តម យុន ចាន់ណារិទ្ធ** អគ្គនាយករង ប.ស.ស. តំណាង **ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចូលរួមធ្វើបទបង្ហាញ និងធ្វើជាវាគ្មិន ក្នុងកិច្ចពិភាក្សាស្តីពី "ប្រព័ន្ធសន្តិសុខសង្គមដែលឆ្លើយតបទៅនឹងការផ្លាស់ប្តូររចនាសម្ព័ន្ធទីផ្សារការងារ និងនិន្នាការនៃភាពមានការងារធ្វើ" ជូនសិក្ខាកាមជាតិ និងអន្តរជាតិ ក្នុងសន្និសីទថ្នាក់ជាតិ ស្តីពីសេដ្ឋកិច្ចការងារ ឆ្នាំ២០២៥ ក្រោមប្រធានបទ "ការរៀបចំអនាគតការងារនៅកម្ពុជា៖ ជំនាញ មុខរបរនិងការងារ និងការគាំពារសង្គម សំដៅបង្កើតទីផ្សារការងារដែលមានភាពធន់"។

សន្និសីទថ្នាក់ជាតិខាងលើនេះ ត្រូវបានរៀបចំឡើង ដើម្បីបើកលំហរជាវេទិកាសម្រាប់ជំរុញកិច្ចសហការ និងការផ្លាស់ប្តូរចំណេះដឹងតាមរយៈការចែករំលែកលទ្ធផលនៃការសិក្សាស្រាវជ្រាវ និងនវានុវត្តន៍ថ្មីៗ។ សន្និសីទនេះក៏ផ្តល់ឱកាសក្នុងការស្វែងយល់ស៊ីជម្រៅអំពីបញ្ហាប្រឈម និងដំណោះស្រាយជាយុទ្ធសាស្ត្រក្នុងទីផ្សារការងារនៅកម្ពុជា សំដៅដល់ការតម្រង់ទិសទស្សនវិស័យការងាររបស់កម្ពុជានាពេលអនាគត ឱ្យមានសង្គតិភាពនឹងការវិវត្តនៃសេដ្ឋកិច្ចសង្គម និងជាការចូលរួមចំណែកកសាងមូលដ្ឋានគ្រឹះដ៏រឹងមាំ ឆ្ពោះទៅសម្រេចបាននូវចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០។

សូមបញ្ជាក់ថា៖ សន្និសីទថ្នាក់ជាតិខាងលើនេះ ត្រូវបានរៀបចំឡើងចំនួន ២ថ្ងៃ គឺចាប់ពីថ្ងៃទី១៥ ដល់ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២៥ ប្រព្រឹត្តទៅដោយផ្ទាល់នៅសណ្ឋាគារសុខា ភ្នំពេញ ដែលមានការចូលរួមពីតំណាងក្រសួងស្ថាប័ន អង្គភាពពាក់ព័ន្ធ អង្គការជាតិ-អន្តរជាតិ និងដៃគូអភិវឌ្ឍន៍ផងដែរ៕

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# ថ្នាក់ដឹកនាំ និងមន្ត្រី នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ទទួលបានការផ្សព្វផ្សាយស៊ីជម្រៅអំពី "សិទ្ធិ កាតព្វកិច្ច និងអត្ថប្រយោជន៍របស់សមាជិក ប.ស.ស." តាមរយៈបេឡាជាតិសន្តិសុខសង្គម

## កម្រងរូបភាពសកម្មភាព










នាព្រឹកថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២៥ **ឯកឧត្តម យុន ចាន់ណារិទ្ធ** អគ្គនាយករង ប.ស.ស. តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ម៉េង ហុង** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប.ស.ស. នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និង **ឯកឧត្តម គុយ សាវុធ** ទីប្រឹក្សាអមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តំណាង **ឯកឧត្តម ម៉ី វ៉ាន់** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ បានអញ្ជើញជាសហអធិបតីភាពបើកសិក្ខាសាលាផ្សព្វផ្សាយស្តីពី "សិទ្ធិកាតព្វកិច្ច និងអត្ថប្រយោជន៍របស់សមាជិក ប.ស.ស." ជូនដល់ថ្នាក់ដឹកនាំ និងមន្ត្រីនៃអគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដោយមានអ្នកចូលរួមប្រមាណជាង១០០រូប នៅមជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច ដែលសិក្ខាសាលានេះ រៀបចំឡើងក្នុងគោលបំណងលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិ កាតព្វកិច្ច និងអត្ថប្រយោជន៍របបសន្តិសុខសង្គម ដែលសមាជិក ប.ស.ស. ត្រូវទទួលបាន។

ក្នុងឱកាសនោះដែរ លោក សុក បូរ៉ា ប្រធាននាយកដ្ឋានតាវកាលិកសន្តិសុខសង្គម នៃ ប.ស.ស. បានធ្វើបទបង្ហាញស្តីពី "ការអនុវត្តរបបសន្តិសុខសង្គម" ដោយរួមមាន៖ ផ្នែកហានិភ័យការងារ ផ្នែកថែទាំសុខភាព និងផ្នែកប្រាក់សោធន ការផ្តល់ប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល ព្រមទាំងអត្ថប្រយោជន៍ផ្សេងៗ ដូចមានចែងក្នុងបទប្បញ្ញត្តិ នៃច្បាប់ស្តីពីរបបសន្តិសុខសង្គម ជូនដល់អ្នកចូលរួមក្នុងសិក្ខាសាលា ព្រមទាំងឆ្លើយតបយ៉ាងក្បោះក្បាយទៅនឹងសំណួរមួយចំនួនពីសំណាក់ថ្នាក់ដឹកនាំ និងមន្ត្រី នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដើម្បីជម្រះនូវរាល់មន្ទិលសង្ស័យ និងបង្កើនទំនុកចិត្តលើការអនុវត្តរបបសន្តិសុខសង្គម៕

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# ការផ្សព្វផ្សាយ និងបញ្ជ្រាបព័ត៌មាន របស់បេឡាជាតិសន្តិសុខសង្គម ទៅកាន់សាធារណជន ជាពិសេសសមាជិក ប.ស.ស.















© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# តើលោកអ្នកបានស្នើសុំតាវកាលិកពី ប.ស.ស. ដោយមិនចាំបាច់មកដល់ទីស្នាក់ប.ស.ស. ហើយឬនៅ?




កាន់តែស្រួល! លោកអ្នកអាចស្នើសុំតាវកាលិកពី ប.ស.ស. មិនចាំបាច់មកដល់ ប.ស.ស. ទៀតទេ បានដោយខ្លួនឯង ដោយត្រឹមរយៈពេលតែប៉ុន្មាននាទីប៉ុណ្ណោះ ដោយប្រើតែកម្មវិធីទូរសព្ទដៃ ប.ស.ស. (NSSF Member App) របស់បេឡាជាតិសន្តិសុខសង្គម។ **ងាយស្រួល ចំណេញពេលវេលា និង ថវិកា!**

# របៀបប្រើប្រាស់ ការស្នើសុំតាវកាលិកពី ប.ស.ស. តាមកម្មវិធីទូរសព្ទដៃ ប.ស.ស. (NSSF Member App)






















YouTube

សូមស្កែន ដើម្បីទស្សនាវីដេអូណែនាំអំពីការស្នើសុំតាវកាលិកពី ប.ស.ស. តាមកម្មវិធីទូរសព្ទដៃ ប.ស.ស.

**NSSF Member App**

© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# របៀបប្រើប្រាស់ ការស្នើសុំតារាងកាលវិភាគ ប.ស.ស. តាមកម្មវិធីទូរសព្ទដៃ ប.ស.ស. (NSSF Member App) (ត)






















© រក្សាសិទ្ធិដោយបេឡាជាតិសន្តិសុខសង្គម

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងព័ត៌មាន
MINISTRY OF INFORMATION

ក្រសួងព័ត៌មាន

អគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍

General Department of Information and Broadcasting

លេខ: ០៤៤ ព.ស-ណ.អ

ថ្ងៃសុក្រ ១១កើត ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩

រាជធានីភ្នំពេញថ្ងៃទី ៦ ខែមិថុនា ឆ្នាំ២០២៥

## លិខិតអនុញ្ញាត

**យោង ៖** -ប្រកាសលេខ ១០៨ ប្រក.ព.ម ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៤ របស់ក្រសួងព័ត៌មាន

-លិខិតលេខ ៤១០/២២ .ធត.ប្រ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២២ របស់រដ្ឋបាលរាជធានីភ្នំពេញ

-លិខិតស្នើសុំប្តូរឈ្មោះ និងទីតាំង ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២៥ របស់បេឡាជាតិសន្តិសុខសង្គម។

តាមសេចក្តីដូចមានចែងក្នុងយោងខាងលើ អគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍ នៃក្រសួងព័ត៌មាន សូមជម្រាបជូន ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកបេឡាជាតិសន្តិសុខសង្គម ជ្រាបថា អគ្គនាយកដ្ឋានព័ត៌មាន និងសោតទស្សន៍ នៃក្រសួងព័ត៌មាន អនុញ្ញាតឱ្យព្រឹត្តិបត្រ **បេឡាជាតិរបបសន្តិសុខសង្គម** ប្តូរឈ្មោះមកជាព្រឹត្តិបត្រ **បេឡាជាតិសន្តិសុខសង្គម** ដែលសរសេរជាអក្សរកាត់ថា ប.ស.ស. និងមានអាសយដ្ឋានទីស្នាក់ការថ្មីស្ថិតនៅផ្លូវបេតុង ភូមិសំរោង សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ បន្តលិខិតលេខ ៤១០/២២-ធត.ប្រ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២២ របស់រដ្ឋបាលរាជធានីភ្នំពេញ។

ក្នុងដំណើរការផ្សព្វផ្សាយ ត្រូវគោរពអនុវត្តឱ្យបានត្រឹមត្រូវតាមខ្លឹមសារប្រកាស របស់ក្រសួងព័ត៌មាន ធម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មាន។ ករណីប្រព្រឹត្តល្មើស សាមីខ្លួនត្រូវទទួលខុសត្រូវតាមច្បាប់ជាធរមាន។

លិខិតអនុញ្ញាតនេះមានសុពលភាពរយៈពេល ០១ (មួយ)ឆ្នាំ គិតពីថ្ងៃចុះហត្ថលេខាតទៅ។

ព្រឹត្តិបត្រ **បេឡាជាតិសន្តិសុខសង្គម** ត្រូវស្នើសុំបន្តសុពលភាពដើម្បីធ្វើសកម្មភាពការងារលើវិស័យព័ត៌មាន និងសោតទស្សន៍ មុនផុតកំណត់រយៈពេល ៣០ (សាមសិប) ថ្ងៃ។

**អគ្គនាយក**

ផុស_សុវណ្ណ

**ចម្លងជូន៖**

- ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រីក្រសួងព័ត៌មាន
- អគ្គស្នងការនគរបាលជាតិ
- និយ័តករទូរគមនាគមន៍កម្ពុជា
- រដ្ឋបាលរាជធានីភ្នំពេញ
- មន្ទីរព័ត៌មានរាជធានីភ្នំពេញ
  " ដើម្បីជូនជ្រាប "
- ឯកសារ កាលប្បវត្តិ